# MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## *កម្ពុជា៖ ដោះស្រាយឱនភាពប្រជាធិបតេយ្យ ហើយកម្ពុជានឹងរីកចម្រើន នេះបើតាមប្រសាសន៍របស់អ្នករាយការណ៍ពិសេស អ.ស.ប ដែលនឹងចប់អាណត្តិ*

ទីក្រុងហ្សឺណែវ (៣០ មេសា ២០១៥) - អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្ស នៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី នៅថ្ងៃនេះ បានចេញសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះ ខណៈដែលលោកបញ្ចប់អាណត្តិប្រាំមួយឆ្នាំរបស់លោក៖

"រយៈពេលប្រាំមួយឆ្នាំ បានកន្លងផុតទៅយ៉ាងឆាប់រហ័ស។ ខ្ញុំបានមានឯកសិទ្ធិ ក្នុងការធ្វើការជាមួយ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គណបក្សប្រឆាំង និងភាគីពាក់ព័ន្ធជាច្រើនទៀត នៅក្នុងសង្គមកម្ពុជា ក្នុងការសរសេររបាយការណ៍របស់ខ្ញុំ ស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការ សភា ការបោះឆ្នោត និងដីធ្លី និង ក្នុងការតាមមើលការអនុវត្តន៍អនុសាសន៍របស់ខ្ញុំ។ ខ្ញុំមានការពេញចិត្តយ៉ាងខ្លាំង ដោយអនុសាសន៍មួយចំនួន ក្នុងចំណោមអនុសាសន៍ទាំងអស់របស់ខ្ញុំ ត្រូវបានអនុវត្ត ហើយអនុសាសន៍មួយចំនួនទៀត បាន និងកំពុង ស្ថិតក្នុងដំណើរការអនុវត្ត។

កម្ពុជាបានធ្វើដំណើរលើផ្លូវមួយដ៏វែងឆ្ងាយក្នុងអំឡុងពេលនេះ។ របៀបវារៈកំណែទម្រង់ មានការ ជឿនលឿនទៅមុខ ដោយមានការអនុម័តច្បាប់គ្រឹះចំនួនបីស្តីពីប្រព័ន្ធតុលាការ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលផ្តល់ឋានៈរដ្ឋធម្មនុញ្ញដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ក្រោមបទបញ្ជា០០១ ពិនិត្យ ដកហូត ដីសម្បទានសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត និងការ អនុម័តគោលការណ៍ណែនាំមួយចំនួនស្តីពីការបណ្តេញចេញពីដីធ្លី។

នៅពេលជាមួយគ្នានេះដែរ នៅក្នុងវិស័យទាំងនេះ និងវិស័យដទៃផ្សេងទៀត កម្ពុជានៅតែត្រូវធ្វើ ដំណើរដ៏វែងឆ្ងាយតទៅទៀត ដើម្បីសម្រេចតាមកម្រិតបទដ្ឋានអន្តរជាតិ ដែលមានប្រភពកើតចេញពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសនេះបានផ្តល់សច្ចាប័ន និងដើម្បីឲ្យឧត្តមគតិនៃលទ្ធិប្រជាធិបតេយ្យ សេរីឲ្យក្លាយជាការពិតសម្រាប់ប្រជាជនរបស់ខ្លួន។ ច្បាប់គ្រឹះទាំងបីស្តីពីប្រព័ន្ធតុលាការ មួយៗសុទ្ធតែមាន គុណវិបត្តិរបស់វាផ្ទាល់។ ក៏ដូចជាកញ្ចប់នៃការធ្វើកំណែទម្រង់ការបោះឆ្នោត ដែលត្រូវបានអនុវត្ត ដោយ គណបក្សកាន់អំណាច និងគណបក្សប្រឆាំងដែរ។

ជាការពិតណាស់ ការធ្វើកំណែទម្រង់នេះនឹងមិនសម្រេចភ្លាមៗបានឡើយ ក្នុងការធ្វើឲ្យប្រសើរឡើង ដល់ស្ថានភាពសិទ្ធិមនុស្សរបស់ប្រជាជននៅក្នុងប្រទេសនេះ។ កំណែទម្រង់ទាំងនេះមួយចំនួន ប្រហែលជា អាចនឹងឲ្យផលខ្លះក្នុងពេលប្រាំ ឬដប់ឆ្នាំទៀត។ ហើយវឌ្ឍននឹងអាស្រ័យទៅលើការអនុវត្តន៍ច្បាប់ទាំងនេះ

ដោយប្រាកដប្រជា និងដោយយកចិត្តទុកដាក់ព្យាយាម។

បើទោះជារដ្ឋាភិបាលមានកាតព្វកិច្ច ធ្វើជាសសរស្តម្ភសម្រាប់សិទ្ធិមនុស្ស និងធានាឲ្យមានការគោរពសិទ្ធិមនុស្សសម្រាប់ទាំងគ្នា គណបក្សប្រឆាំង ក៏មិនត្រូវធ្វើឲ្យអ្នកទាំងឡាយ ដែលបានបង្ហាញខ្លួនក្នុងចំនួនច្រើនដូចនេះ ដើម្បីគាំទ្រដល់ពួកគេ នៅក្នុងរយៈពេលពីរឆ្នាំមកនេះ ខកចិត្តដែរ។

មតិផ្តាំផ្ញើមុនពេលចាកចេញរបស់ខ្ញុំ ទៅកាន់មេដឹកនាំនៃប្រទេសនេះ ទាំងមេដឹកនាំក្នុងជួររដ្ឋាភិបាល ទាំងមេដឹកនាំក្នុងគណបក្សប្រឆាំង គួរតែមានគោលការណ៍ច្បាស់លាស់នៅពេលធ្វើកិច្ចការអ្វីមួយ។ ដំណើរការកំណែទម្រង់ និងសកម្មភាពអភិបាលកិច្ច គួរតែបានគាំទ្រដោយគោលការណ៍នីត្យានុកូលភាព តម្លាភាពការ ពិគ្រោះយោបល់ និងប្រជាធិបតេយ្យដែលមានការចូលរួម។ របៀបវារៈកំណែទម្រង់នេះ មិនមែនធុរកិច្ចរបស់គណបក្សកាន់អំណាច និងគណបក្សប្រឆាំងតែម្នាក់ឯងឡើយ។ វាគឺជារបៀបវារៈថ្នាក់ជាតិមួយ ដែលតាមរយៈនេះមនុស្សមកពីគ្រប់មជ្ឈដ្ឋាន គួរតែមានឱកាសក្នុងការរួមចំណែក និងមានភាពជាម្ចាស់។

យុវជន ជាពិសេស នៅទីនេះនៅកម្ពុជា ក៏ដូចជានៅកន្លែងជាច្រើនផ្សេងទៀតនៅលើពិភពលោក មានការយល់ដឹងកាន់តែខ្លាំងឡើងអំពីសិទ្ធិរបស់ខ្លួន ហើយនឹងបន្តទាមទារឱ្យជីវិតរស់នៅ និង ការអនុវត្តន៍ឲ្យបានល្អប្រសើរឡើង និងគណនេយ្យភាពរឹងមាំថែមទៀត ពីស្ថាប័នរដ្ឋរបស់ខ្លួន ដើម្បីឲ្យការទាមនោះសម្រេចទៅបាន។ ទន្ទឹមនឹងការផ្សះផ្សានយោបាយរវាងគណបក្សនយោបាយធំៗទាំងពីរ ត្រូវបានទទួលស្វាគមន៍ គណបក្សទាំងនេះ គួរតែខិតខំប្រឹងប្រែងដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សាដែលមានលក្ខណៈទូលំទូលាយថែមទៀត នៅក្នុងសង្គមកម្ពុជា និងដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់ប្រជាជន ដែលសិទ្ធិរបស់ពួកគាត់ទទួលរងការរំលោភបំពាន។

សម្រាប់ស្ថិរភាពពិតប្រាកដ និងយូរអង្វែងនៅក្នុងប្រទេស វាគឺជាការសំខាន់ណាស់ដែលថា ប្រជាជនកម្ពុជា មានអារម្មណ៍ថា ពួកគាត់ត្រូវបានគេបំរើយ៉ាងល្អ (គេបំរើគាត់ មិនមែនគេត្រួតត្រាលើគាត់ទេ) ពីតំណាងនយោបាយរបស់ខ្លួន។ ទំហំដែលពួកគាត់មានក្នុងអារម្មណ៍ ដែលថាផលប្រយោជន៍របស់ពួកគាត់ត្រូវបានគេបំរើ នឹងកំណត់ថាតើពួកគេសម្តែងឆន្ទៈរបស់ខ្លួន តាមរយៈតំណាងរបស់គេ ឬស្វែងរកមធ្យោបាយផ្សេងៗទៀត ដើម្បីធ្វើដូច្នេះ។

ច្បាប់សំខាន់ៗត្រូវបានអនុម័តនាពេលកន្លងមកថ្មីៗនេះ ដោយមិនមានការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យ ហើយនិន្នាការគួរឲ្យព្រួយបារម្ភនេះ ទំនងជានៅតែបន្តមាន ចំពោះច្បាប់ផ្សេងៗទៀត ដែលនឹងអនុម័ត។ ការណ៍នេះ បានបញ្ជូនសារអវិជ្ជមានមួយដល់សាធារណជនថា វិធីគ្រប់គ្រងប្រទេសបែបចាស់ មិនបានផ្លាស់ប្តូរឡើយ  ហើយវាអយុត្តិធម៌ចំពោះអ្នកធ្វើកំណែទម្រង់ពិតប្រាកដ ដែលខ្ញុំជឿថាមាន នៅក្នុងគណបក្សធំៗទាំងពីរ ពួកគាត់បាន និងកំពុងខិតខំធ្វើអស់ពីសមត្ថភាព ស្ថិតក្នុងមធ្យោបាយ និងដែនអំណាចរបស់ខ្លួន។

មតិផ្តាំផ្ញើរបស់ខ្ញុំនេះ គឺដើម្បីបើកឲ្យដំណើរការដ៏មានសារសំខាន់នៃការធ្វើច្បាប់ និងជំនះបាននូវមតិរិះគន់ - មិនមែនជាការច្រានវាទុកចោលឡើយ ប៉ុន្តែវាគឺកម្លាំងនៃការលើកជាអំណះអំណាងរបស់លោកអ្នក

និងបង្ហាញឲ្យឃើញពីឆន្ទៈ ចង់ធ្វើដំណើរលើមាគ៌ាដ៏ល្អបំផុត ដើម្បីដោះស្រាយបញ្ហា ទោះជាបញ្ហានោះ អ្នកជាអ្នកស្នើឡើងក្តី។ ក្នុងវិស័យសិទ្ធិដីធ្លី វិធានការវិសាមញ្ញកំពុងចាត់ឡើងនៅពេលនេះ នោះគឺថាគោលបំណងជាក់លាក់ សម្រាប់គ្រាដំបូងក្នុងអំឡុងពេលនៃអាណត្តិរបស់ខ្ញុំ ដើម្បីយកដីធ្លីរបស់ប្រជាជនដែលត្រូវគេយកនោះ មកឲ្យពួកគាត់វិញ។ វិធានការបែបនេះ មានហេតុផលដ៏រឹងមាំសម្រាប់ក្តីសង្ឃឹម។ ខ្ញុំសូមជម្រុញឲ្យវិធានការដូចនេះ បន្តចាត់ សំដៅដោះស្រាយឲ្យប្រជាជនទាំងឡាយដែលបានបណ្តឹងទាមទារ ប្រកបដោយយុត្តិធម៌ ជាជាងការដោះដោយផ្អែកដោយដំ ឬសម្រាប់ចំណេញខាងនយោបាយ។

ការធានាឯករាជ្យភាពរបស់តុលាការ ត្រូវតែមាន ដោយមិនអាចខ្វះផងដែរ។ ថ្វីបើមានចំណុចវិជ្ជមានមួយចំនួននៃច្បាប់គ្រឹះទាំងបីស្តីពីប្រព័ន្ធតុលាការក្តី ក៏ដំណើរការនៅមិនច្បាស់ស្រឡះក្នុងការបកស្រាយ និងការអនុម័តច្បាប់ នឹងបន្តលាបពណ៌អំពីវិធីដែលច្បាប់ទាំងនេះតាត់តែងឡើង លុះត្រាតែច្បាប់ទាំងនេះ នឹងត្រូវបានធ្វើវិសោធនកម្ម ដើម្បីធានាឯករាជ្យភាពរបស់ស្ថាប័នតែមួយគត់ ដែលបានបង្កើតឡើងដើម្បីផ្តល់ការដោះស្រាយចុងក្រោយនូវវិវាទផ្សេងៗ។

ទន្ទឹមនឹងវាគឺជាផ្លូវមួយដ៏វែងឆ្ងាយ ដែលត្រូវធ្វើដំណើរដើរឆ្ពោះទៅសម្រេចបានចក្ខុវិស័យនៃប្រជាធិបតេយ្យសេរី និងគោលដៅទាំងឡាយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ បាននាំឲ្យមានលិទ្ធិប្រធិបតេយ្យថ្មីមួយសម្រាប់ប្រទេសនេះ ខ្ញុំបញ្ចប់អាណត្តិការងាររបស់ខ្ញុំ ដោយមានការជឿជាក់ទាំងស្រុងថាកម្ពុជានឹងឈានទៅដល់គោលដៅនោះ - ប្រជាជនដ៏សកម្មរបស់កម្ពុជា នឹងធានាឲ្យការណ៍នេះសម្រេចបាន។ ពិតណាស់ នេះគឺជាកិត្តិយស និងឯកសិទ្ធិសម្រាប់ខ្ញុំ ដែលមានលទ្ធភាពអាចធ្វើការរួមចំណែកដល់ការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅប្រទេសនេះ នៅក្នុងដំណាក់កាលជាប្រវត្តិសាស្ត្រនេះ។ ដោយការអះអាងយ៉ាងច្បាស់ថា ខ្ញុំនឹងនៅតែជាមិត្តភក្តិរបស់កម្ពុជាជារៀងរហូត ខ្ញុំសូមជូនពរសព្វសាធុការដល់ប្រជាជនកម្ពុជាទាំងអស់ សូមសម្រេចគោលដៅទាំងនេះ និងក្នុងការកសាងសង្គមមួយ ដែលមានវិបុលភាព ភាពអត់ឱន ភាពសុខដុមរម្យនា សមធម៌ និងយុត្តិធម៌ថែមទៀត សម្រាប់ទាំងអស់គ្នា ក្នុងពេលច្រើន ឆ្នាំទៅមុខ។

ខ្ញុំសូមអរគុណដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប ដែលបានផ្តល់ការទុកចិត្តនិងការជឿជាក់មកលើរូបខ្ញុំ ដោយបានតែងតាំងខ្ញុំឲ្យកាន់មុខតំណែងនេះ ក្នុងខែមីនា ឆ្នាំ២០០៩ និងបានបន្តអាណត្តិរបស់ខ្ញុំជារៀងរាល់ឆ្នាំ ហើយបន្ទាប់មក បានបន្តអាណត្តិពីរឆ្នាំ ពីរដង ដែលករណីនេះមិនធ្លាប់មានពីមុនមក ផ្តល់ឲ្យខ្ញុំនូវភាពឋិតថេរចាំបាច់ ដើម្បីអនុវត្តការងារជាយុទ្ធសាស្ត្រមួយបន្ថែមទៀត។ វាគឺជាឯកសិទ្ធិមួយដ៏ធំសម្បើមដែលបានបម្រើប្រជាជនកម្ពុជា និងក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប រយៈពេលប្រាំមួយឆ្នាំមកនេះ។ ខ្ញុំសូមអរគុណដល់រាជរដ្ឋាភិបាលកម្ពុជា មេដឹកនាំគណបក្សប្រឆាំង សកម្មជនសិទ្ធិមនុស្ស និងសហគមន៍ការទូតអន្តរជាតិនានា ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ ចំពោះកិច្ចសហប្រតិបត្តិការរបស់ខ្លួន ជាមួយខ្ញុំនៅទូទាំងអាណត្តិទាំងមូលរបស់ខ្ញុំ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ដល់បុគ្គលិកទាំងឡាយ ដែលមានការលះបង់ មានការប្តេជ្ញាចិត្ត និងប្រកបដោយវិជ្ជាជីវៈ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ទាំងនៅរាជធានីភ្នំពេញ ទាំងនៅទីក្រុងហ្សឺណែវ ចំពោះការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លារបស់ពួកគេ។

លើសពីនេះទៀត ខ្ញុំសូមអរគុណប្រជាជនកម្ពុជា ជាពិសេស យុវជន ចំពោះការទទួលស្វាគមន៍ ភាពកក់ក្ដៅ និងការឧបត្ថម្ភគាំទ្រដល់រូបខ្ញុំ។

ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប បានតែងតាំងបុគ្គលមួយរូបដែលមានសមត្ថភាពបំផុត គឺសាស្ត្រាចារ្យ រ៉ូណា ស្មីត (Professor Rhona Smith) ដើម្បីស្នងដំណែងរបស់ខ្ញុំ។ ខ្ញុំសង្ឃឹមថារដ្ឋាភិបាលកម្ពុជា នឹងផ្ដល់កិច្ចសហប្រតិបត្តិការរបស់ខ្លួនយ៉ាងពេញទំហឹងជាមួយលោកស្រី និងខ្ញុំសូមជូនពរលោកស្រី សូមទទួលបាន ជោគជ័យគ្រប់ភារកិច្ច ក្នុងការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជា ឈានឆ្ពោះទៅកសាងលទ្ធិប្រជាធិបតេយ្យមួយដ៏រឹងមាំ និងការលើកស្ទួយនីតិរដ្ឋពិតប្រាកដ និងការគោរពកាន់តែខ្លាំងឡើងថែមទៀតនូវសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយ ការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំពេញការក្នុងសមត្ថភាពបុគ្គលលោក ផ្ទាល់។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវី អាជីពមួយរូបនៃគណៈ មេធាវីមីឌីលថឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ាននៃនីតិអន្តរ ជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្ដីអាស៊ាននៃច្បាប់អន្តរជាតិ ដោយការិយា ល័យព័ត៌មាននៃសាកលវិទ្យាល័យខេមប្រ៊ីដជ៍។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖*
http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx

*ដើម្បីអានរបាយការណ៍ចុងក្រោយបំផុត(A/HRC/24/36)របស់អ្នករាយការណ៍ពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស សូមចូលទៅកាន់គេហទំព័រ៖*
*http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក ៖ កញ្ញា អ័លហ្គា ណាកាចូ* (Ms. Olga Nakajo) *តាមរយៈទូរស័ព្ទលេខ* (+៤១ ២២ ៩២៨ ៩៣៤៨ */ អ៊ីម៉េល* onakajo@ohchr.org) *ឬ សរសេរមកកាន់* srcambodia@ohchr.org

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទងមកឈ្មោះ សាប៊ៀរ សែលាយ៉ា (Xabier Celaya) សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉េល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងលើបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គីល៖ Google+** gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR

**ផែកលិបិក្រមសិទ្ធិមនុស្សជាសកល ៖** http://uhri.ohchr.org/en